**វីងយីង(ខេមបូឌា)ហ្គាមេន ហ្វាក់ធើរី អិលធីឌី.**

**អាសយដ្ឋានៈ** ផ្លូវជាតិលេខ 4, ភូមិ សាំងដំរី, ឃុំ ធក់ឈើនាង, ស្រុកអង្គស្នួល, ខេត្តកណ្ដាល,ព្រះរាជាណាចក្រកម្ពុជា

# កិច្ចព្រមព្រៀង ស្ដីពីការព្យួរកិច្ចសន្យាការងារ

## កម្មករនិយោជិតចំនួន១១៨ចាប់ពី ថ្ងៃទី២០ខែមិនា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣

កិច្ចព្រមព្រៀងនេះត្រូវបានរៀបចំធ្វើរវាងរោងចក្រ វីងយីង(ខេមបូឌា)ហ្គាមេន ហ្វាក់ធើរី អិលធីឌី. ដែលមានលោក CHENG KAI WING ជានាយកនិងជាតំណាងរោងចក្រ ហៅកាត់ថាភាគី (ក) តំណាងកម្មករនិយោជិត នៃក្រុមហ៊ុន វីងយីង(ខេមបូឌា)ហ្គាមេន ហ្វាក់ធើរី អិលធីឌី. ហៅកាត់ថាភាគី (ខ)

**ភាគីទាំងពីបានព្រមព្រៀងនិង គ្នាតាមប្រការ និងលក្ខខណ្ឌដូចខាងក្រោមៈ**

**ប្រការ ១**

ភាគី (ក) នឹងរៀបចំព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន១១៨នាក់ គ្រប់ផ្នែក ដោយមូលហេតុខ្វះវត្ថុធាតុដើមនិងគ្មានការបញ្ជាទិញបណ្ដាលអោយគ្មានការងារធ្វើគ្រប់គ្រាន់ចាប់ពីថ្ងៃទី ២០ ខែមិនា ឆ្នាំ ២០២៣ រហូតដល់ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣

**ប្រការ ២**

ក្នុងកំឡុងព្យួរកិច្ចសន្យាការងារភាគី (ក) បានព្រមព្រៀងផ្ដល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតចំនួន **៤៥ ដុល្លា** នៃប្រាក់ឈ្នួលអប្បរមា ក្នុង១ខែ សម្រាប់ កម្មករនិយោជិតម្នាក់ៗ។

**ប្រការ ៣**

ភាគី (ក) ត្រូវបើកប្រាក់ព្យួរការងារនេះនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ និងថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០២៣ តាមរយៈគណនេយ្យ ធនាគា ឯកទេសវីងរបស់កម្មករនិយោជិតម្នាក់ៗ។

**ប្រការ ៤**

ភាគី (ខ) ត្រូវត្រឡប់ចូលធ្វើការវិញនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣ ចំពោះកម្មករនិយោជិតណាដែលមិនបានត្រឡប់មកធ្វើការវិញតាមកាលកំណត់ត្រូវចាត់ទុកថាឈប់អត់ច្បាប់។

ថ្ងៃច័ន្ទ១៣កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ពស២៥៦៦

កណ្ដាលថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៣

**ភាគី(ក)តំណាងក្រុមហ៊ុន**

CHENG KAI WENG

**ភាគី(ខ)តំណាងកម្មករនិយោជិត**